# សំណួរដែលគេសួរជារឿយៗ
# ព័ត៌មានថ្មីៗជុំវិញប្រតិបត្តិការសេវាថែទាំសត្វនៃទីក្រុងឡុងបិច

## តើអ្វីជាសេវាថែទាំសត្វនៃទីក្រុងឡុងបិច និងតើពួកគេធ្វើអ្វីខ្លះ?

សេវាថែទាំសត្វនៃទីក្រុងឡុងបិច (LBACS) ជាការិយាល័យមួយចំណុះក្រោមនាយកដ្ឋានឧទ្យាន កម្សាន្ត និងថែរក្សាសត្វសមុទ្រទីក្រុងឡុងបិច ដែលផ្តល់សេវាគ្រប់គ្រង និងថែទាំសត្វ កម្មវិធី និងធនធានផ្សេងៗជូនដល់សហគមន៍នៃទីក្រុងឡុងបិច, Los Alamitos, Cerritos និងទីក្រុង Signal Hill។ LBACS គាំពារសុខភាព សុវត្ថិភាព និងសុខុមាលភាពរបស់សត្វ ដោយផ្តល់ការថែទាំមានគុណភាព ដល់សត្វប្រមាណ ៤០០០ ក្បាល ជារៀងរាល់ឆ្នាំ។ ការិយាល័យនេះក៏ជួយរកផ្ទះឲ្យសត្វ តាមរយៈការសុំសត្វយកទៅចិញ្ចឹម។ ក្នុងឆ្នាំ ២០២៤ ការិយាល័យ LBACS បានសម្របសម្រួលការសុំសត្វយកទៅចិញ្ចឹមចំនួន ២១៥៩ ក្បាល ដោយជោគជ័យ។

## តើភាពជាដៃគូជាមួយអង្គការ spcaLA មានអ្វីកើតឡើង?

កាលពីថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០២៥ សាលាក្រុងឡុងបិច បានផ្តាច់កិច្ចសន្យជួល និងកិច្ចសន្យាលក់រួចជួលពីម្ចាស់ថ្មីវិញពីដៃគូ spcaLA នេះ ដោយបញ្ចប់ភាពជាដៃគូគ្នាជាមួយសាលាក្រុង ដែលធ្លាប់មាន ២៦ ឆ្នាំមកហើយនេះ។ បច្ចុប្បន្ននេះ សាលាក្រុងបានប្រកាសអំពីព័ត៌មានលម្អិត អំពីថាតើសាលាក្រុងនឹងមានផែនការយ៉ាងដូចម្តេច ដើម្បីពង្រឹង និងពង្រីកប្រតិបត្តិការទៅថ្ងៃអនាគតនៃទីតាំងការិយាល័យ LBACS ដើម្បីកសាងអត្ថប្រយោជន៍យូរអង្វែង សម្រាប់សត្វដែលឋិតក្រោមការថែទាំ និងសេវារបស់សាលាក្រុងឡុងបិច និងសេវាដែលការិយាល័យ LBACS ផ្តល់ជូនក្រុងឡុងបិច និងសហគមន៍មូលដ្ឋាន ដែលទទួលសេវាពីស្ថាប័ននេះ។

## តើសាលាក្រុងចុះកិច្ចសន្យាអ្វីខ្លះជាមួយ spcaLA?

សាលាក្រុងធ្លាប់ចុះកិច្ចសន្យាពីដំបូង ជាមួយ spcaLA ក្នុងឆ្នាំ ១៩៩៨ ដើម្បីដោះស្រាយបញ្ហានៃអត្រាចាក់ថ្នាំសម្លាប់សត្វដ៏ច្រើនសន្ធឹកសន្ធាប់ នៅទីក្រុងឡុងបិច ដែលកើតឡើងនៅតាមទីជម្រកសត្វផ្សេងៗទៀតរបស់សាលាក្រុង។ ការចុះកិច្ចសន្យានៅពេលនោះ គឺដើម្បីរកមើលវិធី ប្រសើរមួយ ដើម្បីសត្វដែលគេនាំមកកាន់ទីតាំងនោះ។

## តើអ្វីជាកិច្ចសន្យជួល និងកិច្ចសន្យាលក់រួចជួលពីម្ចាស់ថ្មីវិញ?

សាលាក្រុងជាម្ចាស់កម្មសិទ្ធិលើដី ដែលជាទីតាំងរបស់ការិយាល័យ LBACS បច្ចុប្បន្ន។ តាមកិច្ចព្រមព្រៀង សាលាក្រុងបានជួលដីនោះទៅ spcaLA ក្នុងមួយឆ្នាំ ១២០ ដុល្លារ ជាថ្នូរនឹងការណ៍ដែលអង្គការនេះ សាងសង់ និងបើកដំណើរការទីតាំងទំនើបមួយ ដែលផ្តល់កន្លែងសម្រាប់គ្រប់គ្រងសត្វដោយការិយាល័យ LBACS នេះផង និងជាមជ្ឈមណ្ឌលសុំសត្វយកទៅចិញ្ចឹម ដោយគ្រប់គ្រងដោយ spcaLA ផង។ ក្នុងកិច្ចព្រមព្រៀងនេះ អង្គការទាំងពីរត្រូវសហការគ្នា ដើម្បីជួយគ្នាបំពេញគោលដៅរបស់ខ្លួននៅពេលនោះ។ ក្នុងកិច្ចព្រមព្រៀងនេះដែរ សាលាក្រុងបង់ថ្លៃ ៥០% នៃថ្លៃដំណើរការសម្រាប់ទីតាំងទាំងមូល និងមានសិទ្ធិក្នុងការប្រើប្រាស់ទីធ្លារួមគ្នាជាមួយ spcaLA នៅក្នុងបរិវេណនៃទីតាំងនោះ។

## តើសេវាអ្វីខ្លះដែល spcaLA ធ្លាប់បានផ្តល់ ជំនួសមុខឲ្យ LBACS?

តាមកិច្ចព្រមពៀងជួល និងកិច្ចព្រមព្រៀងលក់រួចជួលពីម្ចាស់ថ្មីវិញនោះ តាំងពីឆ្នាំ ២០០១ អង្គការ spcaLA បានទទួលខុសត្រូវ ក្នុងការចាត់ចែងប្រតិបត្តិការនៃមជ្ឈមណ្ឌលសុំសត្វយកទៅចិញ្ចឹម ដែលឋិតនៅទីតាំង LBACS (7700 E. Spring St.) ដែលក្នុងពេលជាមួយគ្នានោះ សាលាក្រុងផ្តោតលើបញ្ហាធ្ងន់ពាក់ព័ន្ធនឹងការគ្រប់គ្រងសត្វ ការចាប់សត្វអនាថា និងសេវាថែទាំសម្រាប់សហគមន៍។ តាមកិច្ចព្រមព្រៀងនោះ អង្គការ spcaLA ក៏ទទួលខុសត្រូវដែរ ខាងថែរក្សា និងជួសជុលទីតាំងនោះ។

## ហេតុដូចម្តេចបានជាសាលាក្រុងផ្តាច់ដៃគូជាមួយ spcaLA?

កិច្ចព្រមព្រៀងជួល និងកិច្ចព្រមព្រៀងលក់រួចជួលពីម្ចាស់ថ្មីវិញនោះ ត្រូវបានលុបចោល ក្នុងន័យដើម្បីជាឧត្តមប្រយោជន៍សម្រាប់សត្វ ដែលឋិតក្រោមការមើលថែរបស់ការិយាល័យ LBACS និងសហគមន៍ដែលសាលាក្រុងបម្រើ។ ស្របពេលដែលមានក្តីកង្វល់ផ្សេងៗទៀត និងការបំពានកិច្ចសន្យា ដែលឈានរហូតដល់ការផ្តាច់កិច្ចសន្យានេះ សាលាក្រុងសូមពន្យល់ជាបីចំណុច៖

១) ប៉ុន្មានឆ្នាំកន្លងទៅនេះ អង្គការ spcaLA គ្រប់គ្រងជាង ៥០% នៃទីតាំងនេះ ដែលបង្ខំឲ្យសាលាក្រុងកាត់បន្ថយផែនការប្រតិបត្តិការរបស់ខ្លួនជាលំដាប់។ ប្រការនេះបណ្តាលឲ្យប៉ះពាល់ជាអវិជ្ជមានដល់ប្រតិបត្តិការរបស់ការិយាល័យ LBACS ដ្បិតទីជម្រកសត្វនោះមានផ្ទុកសត្វពេញចំណុះ ឬលើសចំណុះ ដែលប៉ះពាល់ដល់សុខភាព និងសុខុមាលភាពរបស់សត្វនៅក្នុងទីជម្រកនោះ។ បច្ចុប្បន្ននេះ សាលាក្រុងបានការអនុញ្ញាតឲ្យចូលទៅកាន់តែ ១៩% ប៉ុណ្ណោះនៃទីតាំងនោះ។ សាលាក្រុង

1. ១) ប៉ុន្មានឆ្នាំកន្លងទៅនេះ អង្គការ spcaLA គ្រប់គ្រងជាង ៥០% នៃទីតាំងនេះ ដែលបង្ខំឲ្យសាលាក្រុងកាត់បន្ថយផែនការប្រតិបត្តិការរបស់ខ្លួនជាលំដាប់។ ប្រការនេះបណ្តាលឲ្យប៉ះពាល់ជាអវិជ្ជមានដល់ប្រតិបត្តិការរបស់ការិយាល័យ LBACS ដ្បិតទីជម្រកសត្វនោះមានផ្ទុកសត្វពេញចំណុះ ឬលើសចំណុះ ដែលប៉ះពាល់ដល់សុខភាព និងសុខុមាលភាពរបស់សត្វនៅក្នុងទីជម្រកនោះ។ បច្ចុប្បន្ននេះ សាលាក្រុងបានការអនុញ្ញាតឲ្យចូលទៅកាន់តែ ១៩% ប៉ុណ្ណោះនៃទីតាំងនោះ។ សាលាក្រុងបានព្យាយាមជាច្រើនដង ដើម្បីដោះស្រាយបញ្ហាទាំងនេះ ជាមួយអង្គការ spcaLA ប៉ុន្តែមិនបានផល។
2. ២) អង្គការ  spcaLA បំពានក្រមរបស់សាលាក្រុងឡុងបិចត្រង់ផ្នែកទី 6.16.190(J)(3) ដែលតម្រូវឲ្យស្ថាប័ននេះនេះ ធ្វើរបាយការណ៍អំពីការសុំសត្វយកទៅចិញ្ចឹម ការផ្ទេរ ឬលក់សត្វ ដែលរបាយការណ៍ចុងក្រោយបំផុតសាលាក្រុងទទួលបាន គឺមានត្រឹមឬនៅមុនថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០២០ ឯណោះ។ របាយការណ៍អំពីការសុំសត្វយកទៅចិញ្ចឹម គឺជាវិធានការទទួលខុសត្រូវមួយ ដែលជាលក្ខខណ្ឌតម្រូវរបស់សាលាក្រុង ដើម្បីធានាឲ្យមានការរាយការណ៍ត្រឹមត្រូវ និងមានតម្លាអំពីប្រតិបត្តិការនៅក្នុងដែនសមត្ថកិច្ចរបស់សាលាក្រុង។ អង្គការ spcaLA បានព្រងើយកន្តើយ មិនព្រមដាក់របាយការណ៍ទាំងនេះ រហូតដល់ទៅជិតប្រាំឆ្នាំ។ ច្បាប់កំណត់ឲ្យអង្គការដាក់របាយករណ៍រាល់ឆ្នាំ។ អង្គការនេះក៏មិនបញ្ហាញឆន្ទៈ ក្នុងការផ្តល់ព័ត៌មានអ្វីមួយ ពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ខ្លួន។ ប្រការនេះធ្វើឲ្យល្អក់កករដល់ភាពជាដៃគូរបស់យើងជាមួយអង្គការនេះជាហូរហែកន្លងមក។
3. ៣) ប៉ុន្មានឆ្នាំកន្លងទៅនេះ អង្គការ spcaLA កាត់បន្ថយយ៉ាងគំហុកក្នុងការទទួលយកសត្វពីLBACS ដើម្បីឲ្យគេសុំយកទៅចិញ្ចឹមខាងក្រៅ។ ដើម្បីជាឯកសារយោង កាលពីឆ្នាំ ២០១១ អង្គការនេះទទួលសត្វដែលគេសុំយកទៅចិញ្ចឹមចំនួន ២៨៥៦ ក្បាល ប៉ុន្តែនៅឆ្នាំ ២០២៤ ពួកគេទទួលតែ ៧៦ ក្បាលប៉ុណ្ណោះ។ ចំនួននេះបង្ហាញអំពី

ការថយចុះជាង ៩៧%។ ប្រការនេះបង្ខំឲ្យការិយាល័យ LBACS បង្កើនការប្រឹងប្រែងក្នុងការសុំសត្វយកទៅចិញ្ចឹម ដើម្បីកាត់បន្ថយភាពជោរជន់លើសចំណុះនៃសត្វនៅក្នុងទីជម្រក និងស្ថានភាពសុខុមាលភាពរបស់សត្វដទៃទៀត។ ក្នុងពេលជាមួយគ្នានេះ LBACS ក៏បន្តកិច្ចការគ្រប់គ្រងសត្វដែលមានបញ្ហាធ្ងន់ និងផ្តល់សេវាថែទាំសត្វទាំងនោះ។ តាមកិច្ចសន្យា ការសុំសត្វយកទៅចិញ្ចឹមនេះ គឺជាការទទួលខុសត្រូវជាចម្បងរបស់អង្គការ spcaLA។

## តើ spcaLA កាត់បន្ថយការសុំសត្វយកទៅចិញ្ចឹមរបស់ខ្លួនឬ?

ចាប់តាំងពីឆ្នាំ ២០១១ spcaLA កាត់បន្ថយការទទួលយកសត្វរបស់ LBACS ដែលទុកសម្រាប់ឲ្យគេសុំយកទៅចិញ្ចឹម កាត់រហូតដល់ជាង ៩៧% ដែលបង្ខំចិត្តឲ្យ LBACS ត្រូវរ៉ាប់រងទាំងសេវាគ្រប់គ្រង ថែទាំសត្វ និងការសុំសត្វយកទៅចិញ្ចឹម។ សូមមើលតារាងខាងក្រោម ដើម្បីបានឃើញអំពីទិន្នន័យប្រៀបធៀបនៃការថយចុះក្នុងការយកសត្វចូលរបស់ spcaLA ចំពោះសត្វដែល LBACS ត្រៀមលក្ខណៈរួចរាល់សម្រាប់ឲ្យគេសុំយកទៅចិញ្ចឹម តាំងពីឆ្នាំ ២០១០។




ខាងលើ៖ តារាងនេះបង្ហាញអំពីការថយចុះនៃការទទួលយកសត្វដាក់ក្នុងទីជម្រក spcaLA នៃសត្វដែល LBACS ត្រៀមលក្ខណៈរួចរាល់សម្រាប់ឲ្យគេសុំយកទៅចិញ្ចឹម (ពណ៌ខៀវស្រាល)។ បើតាមតារាងប្រៀបធៀបនេះ យើងឃើញថា លទ្ធផលកើនជាវិជ្ជមាន ឃើញមានក្នុងតួលេខនៃសត្វឆ្កែ និងឆ្មាដែលត្រៀមលក្ខណៈរួចរាល់សម្រាប់ឲ្យគេសុំយកទៅចិញ្ចឹម ដោយសុំពីទីតាំង LBACS ឬផ្ទេរទៅអង្គការសង្គ្រោះសត្វសម្រាប់ឲ្យគេសុំយកទៅចិញ្ចឹមដែល LBACS រៀបចំធ្វើតាំងពីឆ្នាំ ២០១០ (ពណ៌ខៀវចាស់)។

## កិច្ចព្រមព្រៀងជួល និងលក់រួចជួលពីម្ចាស់ថ្មីវិញនេះ មានសុពលភាពដល់ពេលណា?

នៅមុនផ្តាច់វា កិច្ចព្រមព្រៀងជួល និងលក់រួចជួលពីម្ចាស់ថ្មីវិញរវាង LBACS និង spcaLA ត្រូវមានសុពលភាពរហូតដល់ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០៥៣។ ទីតាំងនោះបានបើកដំណើរការសាធារណៈ កាលពីឆ្នាំ ២០០១។

## តើដល់ពេលណាទើប spcaLA បិទបញ្ចប់ប្រតិបត្តិការនៅទីតាំង LBACS នោះ?

ជាកាយវិការគួរសម សាលាក្រុងនឹងទុកពេលរហូតដល់ ៣០ ថ្ងៃ ឲ្យ spcaLA រើទៅទីតាំងប្រតិបត្តិការថ្មីរបស់ខ្លួន។ បើតាមស្តង់ដា គឺអង្គការនេះត្រូវរើចេញក្នុងរយៈពេលបីថ្ងៃ។ ប៉ុន្តែដោយយើងមានមេត្តាធម៌ និងគិតគូរអំពីសុវត្ថិភាពសត្វដែលឋិតក្រោមការថែទាំរបស់អង្គការ spcaLA ទើបយើងទុកពេលវែងដូច្នេះ។ យើងបានជូនដំណឹងទៅអង្គការ spcaLA  កាលពីថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០២៥។ ដូច្នេះអង្គការនេះមានពេលរហូតដល់ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០២៥ ដើម្បីរើចេញ។

## តើហេតុអ្វីរឿងនេះទើបតែកើតឡើងនៅពេលនេះ ហើយតើសាលាក្រុងមានបានព្យាយាមសម្របសម្រួលអ្វីផ្សេងទៀតដែរឬទេ នៅមុនផ្តាច់កិច្ចព្រមព្រៀងជួល និងលក់រួចជួលពីម្ចាស់ថ្មីវិញនេះ?

សាលាក្រុងបានព្យាយាមជាច្រើនលើកច្រើនគ្រាមកហើយ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដើម្បីដោះស្រាយបញ្ហាបំពានជាក់លាក់នានា និងអនុវត្តចំណាត់ការឲ្យកែដែរ ដូចជាការឆ្លើយឆ្លងគ្នាតាមផ្លូវច្បាប់ រវាងសាលាក្រុង និងអង្គការ spcaLA និងសំណើផ្លូវការសុំឲ្យអង្គការនេះចែករំលែកទីតាំងប្រើប្រាស់រួមនោះជាមួយសាលាក្រុងដែរ ប៉ុន្តែអត់បានផល។

## តើសត្វដែលនៅក្រោមការថែទាំរបស់អង្គការ spcaLA នឹងទៅជាយ៉ាងណា?

សត្វដែលនៅក្នុងទីជម្រក ដែលរក្សាទុកសម្រាប់ការសុំយកទៅចិញ្ចឹម គឺឋិតក្រោមសមត្ថកិច្ចរបស់អង្គការ spcaLA។ ដូច្នេះអង្គការនេះ មានសិទ្ធិអំណាចក្នុងការយកសត្វទាំងនេះទៅតាម ពេលរើទៅទីតាំងថ្មី។ សាលាក្រុងនឹងធ្វើយ៉ាងធានាឲ្យបានថា សត្វទាំងអស់នោះនឹងទទួលបានការមើលថែត្រឹមត្រូវ ក្នុងដំណាក់កាលផ្ទេរទៅកន្លែងថ្មីនោះ មិនថាមើលថែដោយអង្គការ spcaLA ឬដោយសាលាក្រុងនោះឡើយ។ មិនតែប៉ុណ្ណោះ សាលាក្រុងនឹងចាត់ការបន្តការសុំសត្វយកទៅចិញ្ចឹម និងកម្មវិធីសាធារណៈជាច្រើនទៀត។

## តើនេះមានន័យថា មជ្ឈមណ្ឌលសុំសត្វយកទៅចិញ្ចឹមត្រូវបិទទ្វារ និងការសុំសត្វយកទៅចិញ្ចឹមនឹងលែងមាននៅទីតាំងនោះទៀតហើយឬ?

ទោះបីឧសានវាទដែលត្រូវរើចេញ គឺថ្ងៃទី ២៦ ខែ មីនា អង្គការ spcaLA នឹងនឹងបន្តមើលការខុសត្រូវប្រតិបត្តិការមជ្ឈមណ្ឌលធំសម្រាប់សុំសត្វយកទៅចិញ្ចឹម ដែលឋិតនៅទីតាំងនោះ។ ដូច្នេះ ក្នុងពេលនេះ យើងមិនទាន់ដឹងថាតើអង្គការ spcaLA នឹងបិទប្រតិបត្តិការរបស់ខ្លួនភ្លាមៗ នៅទីតាំងមជ្ឈមណ្ឌលសុំសត្វយកទៅចិញ្ចឹមរបស់ខ្លួននោះដែរឬយ៉ាងណា ឬអង្គការនេះនឹងបន្តប្រតិបត្តិការរបស់ខ្លួនរហូតដល់ថ្ងៃផុតកំណត់រើចេញនោះ ឬយ៉ាងណានោះដែរ។ ការសម្រេចបែបណា គឺជាសិទ្ធិរបស់អង្គការ spcaLA។ ប៉ុន្តែ នឹងពុំមានការប្រែប្រួលអ្វីចំពោះកម្មវិធីសុំសត្វយកទៅចិញ្ចឹមរបស់សាលាក្រុង ដែលបច្ចុប្បន្ននេះយកសត្វភាគច្រើននៅទីក្រុងឡុងប៊ិច មករក្សាទុក ដើម្បីត្រៀមលក្ខណៈសម្រាប់ការសុំយកទៅចិញ្ចឹម។

ការិយាល័យ LBACS នឹងនៅបន្តផ្តល់ការសុំសត្វយកទៅចិញ្ចឹម នៅទីតាំងរបស់ខ្លួន ដែលឋិតនៅបរិវេណដដែលនោះ គឺឋិតនៅ (7700 E. Spring St.) នៅជាប់នឹងមជ្ឈមណ្ឌលសុំសត្វយកទៅចិញ្ចឹមរបស់អង្គការ spcaLA នោះឯង។ អតិថិជនអាចទៅកាន់ច្រកចូលនៃទីជម្រកសត្វរបស់ LBACS នៅរៀងរាល់ថ្ងៃ ពុធ ដល់ សុក្រ ពីម៉ោង ១០ ព្រឹក ដល់ ៥ ល្ងាច និងរៀងរាល់ថ្ងៃ សៅរ៍ និង អាទិត្យ ពីម៉ោង ១០ ព្រឹក ដល់ ៣:៣០ ល្ងាច។ កន្លែង LBACS ក៏នឹងនៅតែបន្តកម្មវិធីសុំសត្វយកទៅចិញ្ចឹមបន្តទៀតដែរ ដែលកម្មវិធីនេះមាននៅទូទាំងទីក្រុងឡុងប៊ិច និងសាលាក្រុងសហការគ្នាជាមួយអង្គការដៃគូដែលជួយសង្គ្រោះសត្វ ដើម្បីពង្រឹងកម្មវិធីសុំសត្វយកទៅចិញ្ចឹមនេះ រួមទាំងនាំអង្គការនានា មកឲ្យជួយដល់ការសុំសត្វយកទៅចិញ្ចឹមក្នុងទីជម្រក និងបង្កើនកម្មវិធីសុំសត្វយកទៅចិញ្ចឹមក្នុងសហគមន៍។ កម្មវិធីសុំសត្វយកទៅចិញ្ចឹម នឹងនៅបន្តដាក់បញ្ចូលក្នុងប្រតិទិនរបស់ LBACS និងមានព័ត៌មានច្រើនទៀត ដែលត្រូវចែករំលែកនៅពេលក្រោយ។

## តើនេះមានន័យថាឥឡូវនេះ LBACS នឹងបើកដំណើរការដោយមានលទ្ធភាពទទួលសត្វច្រើនជាងមុនឬ?

LBACS មិនបើកដំណើរការ ដោយទទួលយកសត្វច្រើនជាងមុននៅពេលនេះនៅឡើយទេ ប៉ុន្តែកន្លែងនេះសង្ឃឹមថានឹងអាចទទួលសត្វច្រើនជាងមុនទៅថ្ងៃអនាគត។ កាលណាអង្គការ spcaLA ចាកចេញទៅដោយទុកកន្លែងទំនេរឲ្យយើង LBACS នឹងវាយតម្លៃស្ថានភាពនៃកន្លែងទំនេរនោះ និងដោះស្រាយបញ្ហាជួលជុលថែទាំអគារ និងពិនិត្យមើលសេចក្តីត្រូវការចាំបាច់ ដើម្បីរកមើលលទ្ធភាពពង្រីកប្រតិបត្តិការ ឲ្យបាននៅពាសពេញទីតាំងនោះតែម្តង។ កាលណាយើងអាចចូលប្រើប្រាស់ទីតាំងនោះទាំងស្រុង LBACS ដំបូងនឹងផ្តោតលើការកែលម្អគុណភាព ជីវិតសត្វដែលកំពុងឋិតក្នុងការថែទាំរបស់យើងស្រាប់ ដោយយកសត្វឆ្កែ និងឆ្មាដែលមានស្រាប់ចេញទៅកន្លែងរស់នៅដែលធំទូលាយជាងនេះ និងមានទ្រុងធំជាងនេះ សម្រាប់ឆ្កែ និងឆ្មា ដោយដាក់ក្នុងបន្ទប់រួមទូលាយ និងរៀបចំឲ្យមានបន្ទប់ដាច់ដោយឡែកសម្រាប់ដាក់សត្វដែលឈឺថ្កាត់ ដែលជម្រើសនេះយើងអត់ទាន់មាននៅពេលនេះទេ ដោយសារតែខ្វះកន្លែង។

## តើសេវា និងកម្មវិធីរបស់ LBACS នឹងរងផលប៉ះពាល់ដោយសារតែគម្រោងនេះឬទេ?

LBACS មានមោទនភាព ក្នុងការផ្តល់កម្មវិធី និងសេវាជាច្រើន ដែលមានកិច្ចសហការពីសហគមន៍។ សេវា និងប្រតិបត្តិការ នឹងនៅតែបន្តដូចធម្មតា និងថ្លៃសេវានឹងមិនរងផលប៉ះពាល់ទេ។ នៅពេលក្រោយ សាលាក្រុងនឹងចែករំលែកព័ត៌មាន អំពីផលប៉ះពាល់ណាមួយទៅថ្ងៃអនាគត ចំពោះសាធារណជន ពាក់ព័ន្ធនឹងគម្រោងពង្រីកទីតាំងជម្រកសត្វ នៅពេលដែលយើងមានព័ត៌មានលម្អិតទាំងនោះ។ បញ្ជីរាយនាមគ្រប់កម្មវិធី និងសេវារបស់ LBACS មាននៅ longbeach.gov/acs។

## តើ LBACS នឹងដោះស្រាយការថែទាំជួសជុល និងកែលម្អទីធ្លាបន្ថែមនៅទីតាំងនោះយ៉ាងដូចម្តេច?

ក្នុងលក្ខខណ្ឌរយៈពេលខ្លី LBACS នឹងប្រើប្រាស់សេវាថែទាំជួលជុលទីតាំងនេះ ពីការិយាល័យប្រតិបត្តិការថែទាំនិងជួសជុលរបស់សាលាក្រុង ក្នុងពេលដែលសាលាក្រុងកំពុងសិក្សាដើម្បីកំណត់ផែនប្រតិបត្តិការរយៈពេលមធ្យម និងវែង។ ថវិកា និងបុគ្គលិកបន្ថែម នឹងអាចត្រូវការ ដើម្បីជួយទ្រទ្រង់ការចំណាយជាបន្តបន្ទាប់ជាច្រើន ដូចជាថ្លៃទឹកភ្លើង និងថ្លៃថែទាំជួសជុលទូទៅ ថ្លៃអាហារសត្វ និងគ្រឿងផ្គត់ផ្គង់ និងការកែសោភ័ណភាព និងកែលម្អទីធ្លាថ្មីនោះ។

## តើអ្វីខ្លះជាការកែប្រែប្រតិបត្តិការផ្សេងៗទៀតសម្រាប់ LBACS?

ចាប់ពីអំណេះតទៅ អនាគតរបស់ LBACS មានសង្ឃឹម។ តាមរយៈនៃការប្រែប្រួលនេះ LBACS នឹង៖

- បង្កើនភាពសុខសាន្ត និងសុខុមាលភាពនៃសត្វក្នុងទីជម្រក ដោយផ្តល់កន្លែងរស់នៅដល់សត្វឆ្កែ និងឆ្មាឲ្យធំទូលាយ និងមានខ្យល់អាកាសចេញចូលច្រើនជាងមុន។ ប្រការនេះ បង្កើតបរិយាកាសឲ្យសត្វមានភាពស្ងាត់ស្ងៀមជាងមុន ស្លូតជាងមុន និងឈានទៅជំរុញឲ្យមានការសុំសត្វយកទៅចិញ្ចឹមកាន់តែច្រើន និងកាត់បន្ថយអត្រានៃការសម្លាប់សត្វចោល។
- កាត់បន្ថយបញ្ហាជំងឺ និងសុខភាពនៅក្នុងទីជម្រករួម ដោយយើងនឹងបង្កើតឲ្យមានកន្លែងដាច់ដោយឡែក សម្រាប់ដាក់សត្វដែលឈឺ និងត្រូវព្យាបាល។ ចំណុចនេះ នឹងកាត់បន្ថយរយៈពេលដែលសត្វត្រូវនៅក្នុងទីជម្រក និងបង្កើនភាពវិជ្ជមានច្រើនទៀតសម្រាប់សត្វនៅក្នុងទីជម្រកនេះ។
- អនុវត្តភាពជាដៃគូគ្នាជាមួយអង្គការសង្គ្រោះសត្វ ដើម្បីពង្រឹងការសុំយកសត្វទៅចិញ្ចឹម និងជោគជ័យក្នុងនាំអង្គការជាដៃគូ មកជួយទ្រទ្រង់កម្មវិធីសុំសត្វចិញ្ចឹមនៅទីជម្រក ពង្រីកកម្មវិធីសហគមន៍ ដើម្បីទាក់ទាញអ្នកសុំសត្វយកទៅចិញ្ចឹម និងអនុវត្តសេវាដទៃទៀតសម្រាប់ថែទាំសត្វនៅទីតាំងនោះ។
- ពង្រឹងភាពជាដៃគូគ្នារវាង LBACS ដៃគូអង្គការសង្គមស៊ីវិលមិនរកប្រាក់កម្រៃ និងសហគមន៍ ដោយការបង្កើនថវិកាបរិច្ចាគ និងជំនួយហិរញ្ញវត្ថុសម្រាប់គម្រោងរបស់ទីជម្រកសត្វ។
- អនុវត្តសេវាថែទាំសត្វ និងថ្នាំសង្កូវសម្រាប់សត្វចិញ្ចឹមដែលមានតម្លៃទាប និងចំនួនច្រើន ដោយសាងសង់អគារពេទ្យសត្វក្នុងទីជម្រកផ្ទាល់ ដើម្បីងាយស្រួលធ្វើការ និងមានជម្រើសថែទាំសត្វចិញ្ចឹមដែលធូរថ្លៃ សម្រាប់ពលរដ្ឋសហគមន៍។ ការធ្វើដូច្នេះបាន គឺនឹងជួយជំរុញការសុំសត្វយកទៅចិញ្ចឹម និងកាត់បន្ថយអត្រាដែលយកសត្វមកទុកនៅទីជម្រក។
- កាត់បន្ថយចំនួនសត្វដែលកើនលើសកំណត់ ដោយអនុវត្តវិធានការទុកដាក់សត្វក្នុងផ្ទះកុំឲ្យរួចចេញទៅក្រៅ ក្រៀវសត្វ និងកម្មវិធីយកសត្វទៅប្រគល់ជូនម្ចាស់វិញ ដោយសហការគ្នាជាមួយអង្គការដៃគូ។
- បន្តផ្តល់វគ្គបង្ហាត់សត្វឆ្កែ ដែលបើកជាសាធារណៈ រួមមានបន្ថែមជំនួយកែចរិតឆ្កែកាច ដោយឥតគិតថ្លៃ តាមរយៈអង្គការជាដៃគូដែរ។

## តើការផ្លាស់ប្ដូរនេះ អាចប៉ះពាល់ដល់ថវិកាប្រតិបត្តិការរបស់ការិយាល័យនេះឬទេ?

ការផ្លាស់ប្ដូរនេះ គឺយើងរំពឹងទុកថានឹងមានការកើនឡើងនៃថវិកាដែលមានស្រាប់របស់ការិយាល័យនេះ។ ការកើនឡើងថវិកានេះ គឺដើម្បីដោះស្រាយបញ្ហាទីធ្លាបន្ថែម និងតម្រូវការបុគ្គលិកបន្ថែម។ ចំនួនថវិកាជាក់លាក់ប៉ុន្មាន នឹងត្រូវពិនិត្យមើលឡើងវិញ ដែលនេះជាផ្នែកមួយនៃដំណើរការថវិកា។ ថវិកានឹងអាចត្រូវការចាំបាច់ ដើម្បីរើសបុគ្គលិកថែទាំសត្វបន្ថែមទៀត និងត្រូវការក្រុមថែទាំជួសជុលនៅក្នុងទីតាំងផ្ទាល់ និងត្រូវការថវិកាសម្រាប់ការចំណាយប្រតិបត្តិការជាបន្តបន្ទាប់ជាច្រើនផ្សេងទៀត ដូចជាថ្លៃទឹកភ្លើងប្រចាំឆ្នាំ និងថ្លៃថែទាំជួលជុលទូទៅ ចំណីអាហារសត្វ និងគ្រឿងផ្គត់ផ្គង់ និងការរក្សាសោភ័ណភាព និងកែលម្អទីធ្លាថ្មីនោះ។ បច្ចុប្បន្ននេះ LBACS កំពុងបើកដំណើរការដោយមានបុគ្គលិកពេញម៉ោង ៥១ នាក់ និងថវិកាប្រចាំឆ្នាំ ៧,៨ លានដុល្លារ។

## តើអ្វីគំរូសេវាសង្គ្រោះ និងមេត្តាករុណា (Compassion Save)?

គំរូសេវា Compassion Saves នេះផ្ដោតលើការការពារសត្វក្នុងទីជម្រក ដោយបង្កើតបរិយាកាសអំណោយផលល្អសម្រាប់ថែទាំសត្វ។ LBACS កំពុងធ្វើឲ្យមានផលជាវិជ្ជមាន និងយូរអង្វែង និងបង្កើតឲ្យមានអនាគតល្អសម្រាប់សត្វចិញ្ចឹម និងសត្វដទៃទៀតនៅក្នុងទីក្រុងឡុងប៊ិច តាមរយៈការចុះផ្សព្វផ្សាយដល់មូលដ្ឋាន និងកិច្ចសហប្រតិបត្តិការ ភាពជាដៃគូជិតស្និទ្ធជាមួយអង្គការថែទាំសត្វ សេវាអប់រំ ណែនាំ និងគាំពារ និងកម្មវិធីច្នៃប្រឌិត។

## តើខ្ញុំអាចយល់ដឹងបន្ថែមអំពី LBACS នៅឯណា?

ព័ត៌មានបន្ថែមអំពី LBACS រួមទាំងសេវា កម្មវិធី និងព្រឹត្តិការណ៍ជាច្រើនទៀតផង មាននៅ longbeach.gov/acs និងតាមដានយើងតាមរយៈ @lbanimalcare លើហ្វេសប៊ុក និង Instagram។

## បើខ្ញុំមានសំណួរ តើខ្ញុំត្រូវទាក់ទងនរណា?

បើពលរដ្ឋសហគមន៍មានសំណួរ សូមសរសេរអ៊ីម៉េលទៅកាន់ LBACSCommunications@longbeach.gov។ សូមទុកពេលចំនួនប្រាំទៅប្រាំពីថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីយើងខ្ញុំរៀបចំឆ្លើយតបទៅវិញ។

CITY OF LONG BEACH